**សហព័ន្ធខ្មែរកម្ពុជាក្រោម**
KHMERS KAMPUCHEA-KROM FEDERATION
Asia – Australia – Europe – North America

KKF. P. O . Box 0193. Pennsauken, NJ 08110 (U.S.A.) Tel: (856) 655 3838
www.khmerkrom.net / www.khmerkrom.org

# សេចក្តីថ្លែងការណ៍

## ជុំវិញនយោបាយវិវឌ្ឍន៍ចុងក្រោយ នៅកម្ពុជា

សហព័ន្ធខ្មែរកម្ពុជាក្រោម មានការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះការចាប់ខ្លួន លោក **កឹម សុខា** ជាប្រធានគណបក្សសង្គ្រោះជាតិ កាលពីវេលាម៉ោង ០០:៣៥នាទី រំលងអាធ្រាត្រ ចូលថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ ២០១៧ នៅគេដ្ឋានរបស់លោក ស្ថិតនៅក្នុងសង្កាត់ បឹងកក់ ២ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។ ការចាប់ខ្លួន លោក **កឹម សុខា** ទាំងមានអភ័យឯកសិទ្ធិសភារបស់អាជ្ញាធរកម្ពុជា គឺជាទង្វើរំលោភសិទ្ធិ និងបំពានច្បាប់រដ្ឋធម្មនុញ្ញ ជាអ្នកតំណាងរាស្ត្រ ។

ព្រឹត្តិការណ៍ថ្មីៗចុងក្រោយ នៅប្រទេសកម្ពុជា មានការបិទវិទ្យាស្ថានប្រជាធិបតេយ្យ (NDI) ការបិទប្រពន្ធផ្សព្វផ្សាយព័ត៌មានឯករាជ្យ វិទ្យុអាស៊ីសេរី (RFA), វិទ្យុសំឡេងសហរដ្ឋអាមេរិក (VOA), វិទ្យុសំឡេងប្រជាធិបតេយ្យ (VOD), កាសែតខាមបូឌាលី (The Cambodia Daily) និងការចាប់ខ្លួន លោក **កឹម សុខា** ជាប្រធានគណបក្សប្រឆាំងនៅកម្ពុជា បានធ្វើឱ្យសិទ្ធិសេរីភាព នៃការបញ្ចេញមតិកាន់តែចង្អៀត និង លទ្ធិប្រជាធិបតេយ្យ ដើរថយក្រោយ ។

សហព័ន្ធខ្មែរកម្ពុជាក្រោម សូមអំពាវនាវដល់អាជ្ញាធរកម្ពុជា និង តុលាការយុត្តិធម៌ ដោះលែង លោក **កឹម សុខា** ជាបន្ទាន់ និងសម្របសម្រួលនយោបាយដោយសន្តិវិធី ផ្អែកលើគោលការណ៍នីតិរដ្ឋខ្មែរតែមួយ និងសូមអំពាវនាវដល់សហគមន៍អន្តរជាតិ ជួយធ្វើអន្តរាគមន៍ដោះលែង លោក **កឹម សុខា** ចេញពីពន្ធនាគារ ដើម្បីនាំមកនូវសុខសន្តិភាព និង លទ្ធិប្រជាធិបតេយ្យ នៅក្នុងប្រទេសកម្ពុជា ឱ្យកាន់តែរឹងមាំ ។

សហរដ្ឋអាមេរិក, ថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០១៧

**សហព័ន្ធខ្មែរកម្ពុជាក្រោម**